ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ : ១៧២ ដនស/ប្រក/ប.

# ប្រកាស

## ស្តីពី

## ការកែសម្រួលសមាសភាពនៃគណៈកម្មាធិការលទ្ធកម្ម (គ.ល.) និងអង្គភាពលទ្ធកម្ម (អ.ល.)

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/004 ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១២ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៨០ អនក្រ.បក ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១៦ ស្តីពីការបង្កើតអគ្គាធិការដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១៥ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម
- យោងប្រកាសលេខ ១៥៦ ដនស/ប្រក/ប ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១៦ ស្តីពីការកំណត់សមាសភាពនៃគណៈកម្មាធិការលទ្ធកម្ម (គ.ល.) និងអង្គភាពលទ្ធកម្ម (អ.ល.)
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ស ម្រេ ច

**ប្រការ ១._**

កែសម្រួលសមាសភាពនៃគណៈកម្មាធិការលទ្ធកម្ម (គ.ល.) និងអង្គភាពលទ្ធកម្ម (អ.ល.) មានដូចខាងក្រោម៖

**ក. សមាសភាពនៃគណៈកម្មាធិការលទ្ធកម្ម (គ.ល.)**

| | | |
|---|---|---|
| ១. ឯកឧត្តម **ជា សុផារ៉ា** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |



អាសយដ្ឋាន : ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

| | | |
|---|---|---|
| ២. ឯកឧត្តម **ឆាន់ សាផាន** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម **ខ្ញឹម សំអ៊ែល** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៤. ឯកឧត្តម **សេង ឡូត** | អគ្គនាយករដ្ឋបាល | សមាជិក |
| ៥. លោក **សេង សុវណ្ណរ័ត្ននា** | អគ្គនាយករងរដ្ឋបាល | សមាជិក |
| ៦. លោក **ម៉ឹង សុខលាភ** | ប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញកិច្ច | សមាជិក |
| ៧. លោក **ឆូ សុឆូ** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគ និងទំនាក់ទំនងអន្តរជាតិ | សមាជិក |
| ៨. លោក **ខួន បុណ្ណមី** | ប្រធានអង្គភាពលទ្ធកម្ម | លេខាធិការ |

**ខ. សមាសភាពនៃអង្គភាពលទ្ធកម្ម (អ.ល.)**

| | |
|---|---|
| ១. លោក **ខួន បុណ្ណមី** | ប្រធាន |
| ២. លោក **ឡាយ ច័ន្ទឆា** | អនុប្រធាន |
| ៣. លោក **អ៊ឹង ចន្ទសុវណ្ណ** | អនុប្រធាន |
| ៤. លោក **ស៊ូ សុខជាតិ** | សមាជិក |
| ៥. លោកស្រី **ពេជ្រ មរកត** | សមាជិកា |
| ៦. កញ្ញា **ស្រ៊ុន ច័ន្ទរស្មី** | សមាជិកា |
| ៧. កញ្ញា **ជា សុជាតា** | សមាជិកា |

**ប្រការ ២.-**

តួនាទី និងភារកិច្ចនៃគណៈកម្មាធិការលទ្ធកម្ម (គ.ល.) និងអង្គភាពលទ្ធកម្ម (អ.ល.) ត្រូវអនុវត្តឱ្យស្របតាមច្បាប់ស្តីពីលទ្ធកម្មសាធារណៈដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០០១២/០០៤ ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១២ អនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១៥ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៤.-**

នាយកខុទ្ទកាល័យ គ្រប់អគ្គនាយក អគ្គាធិការ គ្រប់ប្រធាននាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានរាយនាមក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ៧

ថ្ងៃ សុក្រ ១២ រោច ខែ ស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៨

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** ៤

**ជា សុផារ៉ា**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ